ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០២៤..៣៧៣.ប្រ.ក...

# ប្រកាស
# ស្តីពី
# ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ១៤-០១៧-១៦១ ប្រ.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងប្រតិបត្តិការនិងអាជីវកម្មពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូស្របតាមមាត្រា ២ ដល់ ៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ធនាគារពាណិជ្ជ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា និងមានបំណងកាន់កាប់អ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ និង/ឬ មានបំណងផ្តល់សេវាទ្រព្យសកម្មគ្រីបតូក្នុងនាមជាបុគ្គលផ្តល់សេវាទ្រព្យសកម្មគ្រីបតូ។

ប្រកាសនេះក៏មានវិសាលភាពអនុវត្តចំពោះនីតិបុគ្គលមានបំណងផ្តល់សេវាទ្រព្យសកម្មគ្រីបតូដូចមានកំណត់ក្នុងប្រការ ២០ នៃប្រកាសនេះ។

លក្ខខណ្ឌនៃការអនុញ្ញាតចំពោះធនាគារពាណិជ្ជ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងការផ្តល់អាជ្ញាបណ្ណដល់នីតិបុគ្គលផ្តល់សេវាទ្រព្យសកម្មគ្រីបតូនឹងត្រូវកំណត់ដោយប្រកាសដោយឡែក។

**ប្រការ ៣.-**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ទ្រព្យសកម្មគ្រីបតូ (Cryptoassets)** សំដៅដល់ឯកតាតម្លៃជាឌីជីថល ដោយប្រើប្រាស់គ្រីបតូក្រាហ្វី (Cryptography) និងបច្ចេកវិទ្យាឌីអិលធី (Distributed ledger technology ឬ DLT) ឬបច្ចេកវិទ្យាប្រហាក់ប្រហែល។ ទ្រព្យសកម្មគ្រីបតូអាចត្រូវបានជួញដូរ ផ្ទេរ និងប្រើប្រាស់សម្រាប់ការទូទាត់ ការវិនិយោគ ឬការទទួលបានទំនិញ/សេវា តាមប្រព័ន្ធឌីជីថល។ ទ្រព្យសកម្មគ្រីបតូនេះរាប់បញ្ចូល ថូខិនទ្រព្យសកម្មប្រពៃណី (Tokenized traditional assets) ទ្រព្យសកម្មគ្រីបតូមិនមានការធានា (Unbacked cryptoassets) ស្តេប៊ិលខ័ញ (Stablecoin) ថូកខិនយូធីលីធី (Utility token) និងថូកខិនមូលបត្រ (Security token)។ ទ្រព្យសកម្មគ្រីបតូនេះមិនរាប់បញ្ចូលរូបិយវត្ថុឌីជីថលរបស់ធនាគារកណ្តាល (Central bank digital currency - CBDC) ទេ។ សម្រាប់គោលបំណងនៃការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូនៃប្រកាសនេះ ទ្រព្យសកម្មគ្រីបតូមិនរាប់បញ្ចូលនូវឯកតាតម្លៃតំណាងឱ្យរូបិយវត្ថុ ឬរូបិយប័ណ្ណ មូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។
- **អ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ (Cryptoassets exposure)** សំដៅដល់ចំនួនទ្រព្យសកម្មគ្រីបតូក្នុងឬក្រៅតារាងតុល្យការ ដែលអាចបង្កឱ្យមានហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និង/ឬ ហានិភ័យសន្ទនីយភាព។ ប្រតិបត្តិការមួយចំនួនដែលអាចបង្កឱ្យមានហានិភ័យប្រតិបត្តិការ ដូចជា ការរក្សាទុកឬគ្រប់គ្រងទ្រព្យសកម្មគ្រីបតូរបស់អតិថិជន ក៏រាប់បញ្ចូលនៅក្នុងអ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ។
- **គ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ (Cryptoasset Service Providers – CASPs)** សំដៅដល់នីតិបុគ្គលផ្តល់សេវា ឬធ្វើប្រតិបត្តិការទ្រព្យសកម្មគ្រីបតូណាមួយសម្រាប់អតិថិជន ដូចជា (ក) ប្តូរទ្រព្យសកម្មគ្រីបតូទៅជារូបិយវត្ថុ/រូបិយប័ណ្ណ ឬទ្រព្យសកម្មគ្រីបតូប្រភេទផ្សេង (ខ) ផ្ទេរទ្រព្យសកម្មគ្រីបតូ និង/ឬ (គ) រក្សាទុក ឬគ្រប់គ្រងទ្រព្យសកម្មគ្រីបតូ។
- **កាបូបអេឡិចត្រូនិក/អ៊ីវ៉ាឡេត (E-wallet)** សំដៅដល់គណនីដែលអាចរក្សាទុកប្រាក់ ឬឯកតាតម្លៃផ្សេងទៀតជាមុននៅក្នុងកម្មវិធីសូហ្វែរឧបករណ៍អេឡិចត្រូនិក ដូចជា កុំព្យូទ័រ ទូរស័ព្ទដៃ ជាដើម ដែលអាចធ្វើប្រតិបត្តិការអនឡាញ និងកត់ត្រាប្រវត្តិប្រតិបត្តិការ។

- **ថូកខិនីយកម្ម (Tokenization)** សំដៅដល់ដំណើរការផ្នែកបច្ចេកវិទ្យា និងគតិយុត្ត ក្នុងការបំប្លែងកម្មសិទ្ធិលើទ្រព្យសកម្ម នៅលើបញ្ជិកាក្នុងប្រព័ន្ធឌីជីថល។
- **ស្តេបិលខ័ញ (Stablecoin)** សំដៅដល់ទ្រព្យសកម្មគ្រីបតូ ដែលអាចរក្សាស្ថិរភាពតម្លៃធៀបនឹងទ្រព្យសកម្មមួយ ឬបណ្តុំនៃទ្រព្យសកម្ម។

## ជំពូកទី ២
## ការបែងចែកទ្រព្យសកម្មគ្រីបតូ

**ប្រការ ៤.-**

ទ្រព្យសកម្មគ្រីបតូត្រូវបានបែងចែកជា ២ ក្រុម គឺ ក្រុម១ និង ក្រុម២។

**ប្រការ ៥.-**

ទ្រព្យសកម្មគ្រីបតូ ក្រុម១ ជាឯកតាតម្លៃជាឌីជីថលនៃឧបករណ៍ហិរញ្ញវត្ថុ ឬទ្រព្យសកម្ម ឬបណ្តុំទ្រព្យសកម្មប្រពៃណី ដែលហៅថា ទ្រព្យសកម្មយោង (Reference assets)។ ទ្រព្យសកម្មគ្រីបតូ ក្រុម១ ត្រូវបានបែងចែកជា ២ ក្រុម ដូចខាងក្រោម៖

១. ទ្រព្យសកម្មគ្រីបតូ ក្រុម១ក ជាឯកតាតម្លៃទ្រព្យសកម្មប្រពៃណីជាឌីជីថល ដែលត្រូវឆ្លងកាត់ដំណើរការថូកខិនីយកម្ម ជាពិសេស ថូកខិនមូលបត្រ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬប្រហាក់ប្រហែល ដើម្បីកត់ត្រាភាពជាម្ចាស់កម្មសិទ្ធិ។ ទ្រព្យសកម្មគ្រីបតូ ក្រុម១ក មានកម្រិតហានិភ័យឥណទាន និងហានិភ័យទីផ្សារ ដូចគ្នានឹងការកាន់កាប់ទ្រព្យសកម្មប្រពៃណី ដូចជា សញ្ញាបណ្ណសាជីវកម្ម ឥណទាន ប្រាក់បញ្ញើ មូលបត្រកម្មសិទ្ធិ ឧបករណ៍និស្សន្ទ ខុម៉ូឌីធី និងសាច់ប្រាក់ក្នុងគណនី (Cash in custody)។

២. ទ្រព្យសកម្មគ្រីបតូ ក្រុម១ខ ជាស្តេបិលខ័ញដែលមានយន្តការស្ថិរភាព (Stabilisation mechanism) ប្រកបដោយប្រសិទ្ធភាព តាមរយៈការរក្សាតម្លៃទ្រព្យសកម្មឬបណ្តុំទ្រព្យសកម្មប្រពៃណីបម្រុង (Reserve assets) ដែលទ្រព្យសកម្មបម្រុងនេះមិនអាចជាទ្រព្យសកម្មគ្រីបតូ ឬ Algorithm-based stablecoins ទេ។

**ប្រការ ៦.-**

ទ្រព្យសកម្មគ្រីបតូអាចត្រូវបានទទួលស្គាល់ក្នុងទ្រព្យសកម្មគ្រីបតូ ក្រុម១ក ឬទ្រព្យសកម្មគ្រីបតូ ក្រុម១ខ ក្នុងករណីបំពេញបានលក្ខខណ្ឌខាងក្រោម៖

១. ទ្រព្យសកម្មគ្រីបតូ ក្រុម១ក ត្រូវ៖

- ប្រើប្រាស់គ្រីបតូក្រាហ្វី និងបច្ចេកវិទ្យាឌីជីថល ឬបច្ចេកវិទ្យាប្រហាក់ប្រហែល ក្នុងការកត់ត្រាកម្មសិទ្ធិ និង
- មានកម្រិតហានិភ័យនិងសិទ្ធិដូចគ្នានឹងទ្រព្យសកម្មយោង។

២. ទ្រព្យសកម្មគ្រីបតូ ក្រុម១ខ ត្រូវមានយន្តការស្ថិរភាពប្រកបដោយប្រសិទ្ធភាព។ យន្តការស្ថិរភាពត្រូវមានលក្ខណៈ ដូចខាងក្រោម៖

- ទ្រព្យសកម្មគ្រីបតូអាចទូទាត់តាមចំនួនកំណត់ជាមុននៃទ្រព្យសកម្មយោង ដែលហៅថា ឯកតាតម្លៃភ្ជាប់ (Peg value)

- យន្តការស្ថិរភាពត្រូវកាត់បន្ថយជាអតិបរមានូវការប្រែប្រួលនៃតម្លៃទីផ្សារទ្រព្យសកម្មគ្រីបតូដោយធៀបនឹងឯកតាតម្លៃភ្ជាប់
- ទ្រព្យសកម្មបម្រុងត្រូវមានព័ត៌មានអំពីកម្មសិទ្ធិគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីអាចផ្ទៀងផ្ទាត់បាន
- ស្តេបិលខ័ញត្រូវបោះផ្សាយដោយគ្រឹះស្ថានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាល ឬអាជ្ញាធរត្រួតពិនិត្យ និង
- ទ្រព្យសកម្មគ្រីបតូត្រូវឆ្លងកាត់តេស្តហានិភ័យទូទាត់ (Redemption risk test) ដោយបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖
  - តម្លៃទ្រព្យសកម្មបម្រុងត្រូវស្មើ ឬលើសតម្លៃភ្ជាប់នៃទ្រព្យសកម្មគ្រីបតូដក់សល់សរុប
  - ទ្រព្យសកម្មបម្រុងត្រូវមានហានិភ័យទីផ្សារ និងហានិភ័យឥណទានក្នុងកម្រិតទាប (ដូចជាអាចបំពេញបានតាមលក្ខខណ្ឌទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ក្នុងអនុបាតក្របខ័ណ្ឌសន្ទនីយភាព) និងត្រូវចារឹកជារូបិយវត្ថុឬរូបិយប័ណ្ណសមាមាត្រនឹងឯកតាតម្លៃភ្ជាប់
  - ការគ្រប់គ្រងទ្រព្យសកម្មបម្រុង ត្រូវមានឯកសារបង្ហាញជាសាធារណៈនូវតម្លៃទ្រព្យសកម្មបម្រុងជាប្រចាំថ្ងៃ និងសមាសធាតុនៃទ្រព្យសកម្មបម្រុងជាប្រចាំសប្តាហ៍ និង
  - ការទូទាត់ទ្រព្យសកម្មគ្រីបតូត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ៥ថ្ងៃនៃថ្ងៃប្រតិទិន។

ក្រៅពីលក្ខខណ្ឌដូចមានកំណត់ខាងលើ ទ្រព្យសកម្មគ្រីបតូ ក្រុម១ក និងក្រុម១ខ ត្រូវមានលក្ខខណ្ឌរួម ដូចខាងក្រោម៖

១. សិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍នៃទ្រព្យសកម្មគ្រីបតូត្រូវកំណត់ឱ្យបានច្បាស់លាស់ អាចអនុវត្តបានតាមផ្លូវច្បាប់ និងរក្សាទុកឯកសារឱ្យបានត្រឹមត្រូវនៅគ្រប់យុត្តាធិការដែលបោះផ្សាយ និងទូទាត់ទ្រព្យសកម្មគ្រីបតូនោះ។ លើសពីនេះ ក្របខ័ណ្ឌច្បាប់អនុវត្តត្រូវធានានូវការទូទាត់ជាស្ថាពរ (Settlement finality)។

២. មុខងារនិងប្រព័ន្ធដំណើរការទ្រព្យសកម្មគ្រីបតូ រួមទាំង បច្ចេកវិទ្យាឌីអិលធី ឬបច្ចេកវិទ្យាប្រហាក់ប្រហែលត្រូវបានរៀបចំដើម្បីកាត់បន្ថយនិងគ្រប់គ្រងហានិភ័យជាអតិបរមា។ ទ្រព្យសកម្មគ្រីបតូដែលប្រើបច្ចេកវិទ្យាឌីអិលធី ឬបច្ចេកវិទ្យាប្រហាក់ប្រហែលដែលជា permissionless ledger មិនចាត់ចូលជាទ្រព្យសកម្មគ្រីបតូ ក្រុម១ ទេ។

៣. នីតិបុគ្គលធ្វើប្រតិបត្តិការទូទាត់ ផ្ទេរ ឬរក្សាទុកទ្រព្យសកម្មគ្រីបតូ ឬ គ្រប់គ្រងឬវិនិយោគទ្រព្យសកម្មបម្រុងត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរត្រួតពិនិត្យ ឬអាជ្ញាធរពាក់ព័ន្ធ។

**ប្រការ ៧.-**

ទ្រព្យសកម្មគ្រីបតូ ក្រុម២ ជាប្រភេទទ្រព្យសកម្មគ្រីបតូដែលមិនមានលក្ខណៈវិនិច្ឆ័យដូចទ្រព្យសកម្មគ្រីបតូ ក្រុម១ ជាពិសេសទ្រព្យសកម្មគ្រីបតូមិនមានការធានា ឬមិនមែនជាថូកខិនទ្រព្យសកម្មប្រពៃណីឬស្តេបិលខ័ញ។

# ជំពូកទី ៣
# អភិបាលកិច្ចហានិភ័យទ្រព្យសកម្មគ្រីបតូរបស់ធនាគារពាណិជ្ជ

## ផ្នែក ១៖ ក្របខ័ណ្ឌអភិបាលកិច្ច

**ប្រការ ៨.-**

ក្រុមប្រឹក្សាភិបាលត្រូវបង្កើត អនុម័ត និងពិនិត្យឡើងវិញជាប្រចាំលើគោលនយោបាយ នីតិវិធី ដំណើរការ និងប្រព័ន្ធសម្រាប់គ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការទ្រព្យសកម្មគ្រីបតូ។ ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយ នីតិវិធី ដំណើរការ និងប្រព័ន្ធទាំងនោះ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដើម្បី កំណត់ វាយតម្លៃ តាមដាន និងដោះស្រាយបញ្ហាហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការទ្រព្យសកម្មគ្រីបតូ ក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់គណៈគ្រប់គ្រងជាន់ខ្ពស់កម្រិតប្រតិបត្តិ។

ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាពចំពោះប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ដោយធានាថាធនាគារពាណិជ្ជ៖

១. មាននីតិវិធី និងចាត់តាំងបុគ្គលិកសម្រាប់អនុវត្តនិងសម្រេចលើការបែងចែកប្រភេទទ្រព្យសកម្មគ្រីបតូស្របតាមលក្ខខណ្ឌដូចមានកំណត់ក្នុងជំពូកទី ២ នៃប្រកាសនេះ ហើយការបែងចែកប្រភេទទ្រព្យសកម្មគ្រីបតូត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាភិបាល

២. មានរចនាសម្ព័ន្ធដើម្បីធានាការអនុលោមតាមកម្រិតអនុគ្រោះហានិភ័យផ្ទៃក្នុង រួមទាំងកម្រិតក្នុងថ្ងៃ និងមាននីតិវិធីកែតម្រូវឱ្យស្របតាមកម្រិតកំណត់វិញ ក្នុងករណីមិនអាចគោរពបានតាមកម្រិតកំណត់ផ្ទៃក្នុងនោះ

៣. មានធនធានមនុស្សគ្រប់គ្រាន់ប្រកបដោយគុណវុឌ្ឍិ ក្នុងការវាយតម្លៃហានិភ័យលើប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ និងតាមដានបច្ចុប្បន្នភាពពីការអភិវឌ្ឍផ្សេងៗក្នុងវិស័យទ្រព្យសកម្មគ្រីបតូ និងស្តង់ដាអន្តរជាតិពាក់ព័ន្ធ និង

៤. មានយន្តការរាយការណ៍សមស្របទាំងកម្រិតក្រុមប្រឹក្សាភិបាល កម្រិតគណៈគ្រប់គ្រងជាន់ខ្ពស់ និងកម្រិតផ្នែកអាជីវកម្ម ដើម្បីឱ្យការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូមានលក្ខណៈបុរេសកម្ម។

**ប្រការ ៩.-**

គោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យត្រូវកំណត់ពីវិសអាប់កែថាយ និងវិសថលើវែនពាក់ព័ន្ធនឹងប្រតិបត្តិការទ្រព្យសកម្មគ្រីបតូចំពោះហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ ដែលរួមបញ្ចូលទាំងហានិភ័យបច្ចេកវិទ្យារបស់ទ្រព្យសកម្មគ្រីបតូ បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង (Information, Communication and Technology - ICT) ហានិភ័យសាយប័រ ហានិភ័យគតិយុត្ត ហានិភ័យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហានិភ័យហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងហានិភ័យលើការវាយតម្លៃទ្រព្យសកម្មគ្រីបតូ (Valuation risk)។

**ប្រការ ១០.-**

គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ នីតិវិធី ដំណើរការ និងប្រព័ន្ធសម្រាប់គ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការទ្រព្យសកម្មគ្រីបតូ ស្របតាមគោលនយោបាយ នីតិវិធី ដំណើរការ និងប្រព័ន្ធសម្រាប់គ្រប់គ្រងហានិភ័យដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

## ផ្នែក ២៖ លក្ខខណ្ឌប្រតិបត្តិការ

**ប្រការ ១១.-**

ធនាគារពាណិជ្ជអាចធ្វើប្រតិបត្តិការ ឬផ្តល់សេវាពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ៖

១. សម្រាប់ខ្លួនឯងផ្ទាល់៖ ធនាគារពាណិជ្ជដែលមានបំណងធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ដូចមានកំណត់ក្នុងប្រការ ៦ នៃប្រកាសនេះ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌនៃការអនុញ្ញាតមានកំណត់ក្នុងប្រការ ១៣ នៃប្រកាសនេះ

២. សម្រាប់អតិថិជនរបស់ខ្លួន៖ ធនាគារពាណិជ្ជដែលមានបំណងផ្តល់សេវាពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ (ដូចមានកំណត់ក្នុងជំពូកទី ៤ នៃប្រកាសនេះ) ដល់អតិថិជន ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ស្របតាមលក្ខខណ្ឌដូចមានកំណត់ក្នុងប្រកាសដោយឡែក។

**ប្រការ ១២.-**

ធនាគារពាណិជ្ជ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូសម្រាប់ខ្លួនឯងផ្ទាល់ ដូចខាងក្រោម៖

១. ការបោះផ្សាយទ្រព្យសកម្មគ្រីបតូ និង

២. ប្រតិបត្តិការដោយផ្ទាល់ ឬដោយប្រយោលពាក់ព័ន្ធនឹងអ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ ក្រុម២ រួមបញ្ចូលទាំងប្រតិបត្តិការគ្រប់ប្រភេទលើទីផ្សារឧបករណ៍និស្សន្ទ ដែលមានទ្រព្យសកម្មសាមីជាទ្រព្យសកម្មគ្រីបតូ ក្រុម២។

**ប្រការ ១៣.-**

ធនាគារពាណិជ្ជដែលមានបំណងធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ដូចមានកំណត់ក្នុងចំណុច ១ នៃប្រការ ១១ ខាងលើ ត្រូវស្នើសុំមកធនាគារជាតិនៃកម្ពុជា ដោយបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១. មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលអនុម័តឱ្យធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងអ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ ជាពិសេសការវាយតម្លៃផលប៉ះពាល់លើស្ថានភាពហិរញ្ញវត្ថុ សន្ទនីយភាព និងសាធនភាព

២. មានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន

៣. មានការចាត់ថ្នាក់ជាទ្រព្យសកម្មគ្រីបតូ ក្រុម១ក ឬ ទ្រព្យសកម្មគ្រីបតូ ក្រុម១ខ ដោយមានភ្ជាប់មកជាមួយនូវព័ត៌មានលម្អិតអំពីការចាត់ថ្នាក់នេះ

៤. មានការពិនិត្យ និងសិក្សាឬហ្មត់ចត់ផ្នែកបទប្បញ្ញត្តិសមស្របលើរចនាសម្ព័ន្ធទ្រព្យសកម្មគ្រីបតូដែលធនាគារពាណិជ្ជមានបំណងកាន់កាប់

៥. មានផែនការអាជីវកម្មពាក់ព័ន្ធអ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ សម្រាប់រយៈពេល ៣ ឆ្នាំ

៦. មានក្របខ័ណ្ឌអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យអ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ ដូចមានកំណត់ក្នុងជំពូកទី ៣ និង

៧. មានឯកសារ ឬព័ត៌មានគាំទ្រផ្សេងៗ តាមការតម្រូវបន្ថែមដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៤.-**

បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងអំពីសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធការស្នើសុំ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ។

## ផ្នែក ៣៖ បទប្បញ្ញត្តិប្រុងប្រយ័ត្ន

**ប្រការ ១៥.-**

ធនាគារពាណិជ្ជត្រូវអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្នជាធរមានលើទ្រព្យសកម្មគ្រីបតូ ក្រុម១ ផ្អែកលើគោលការណ៍ "សកម្មភាពដូចគ្នា ហានិភ័យដូចគ្នា ក្របខ័ណ្ឌបទប្បញ្ញត្តិដូចគ្នា" ដែលអនុវត្តចំពោះទ្រព្យសកម្មប្រពៃណី ទាំងក្នុងបញ្ជិកាធនាគារ និងបញ្ជិកាជួញដូរ ដោយមានកំណត់ក្នុងសេចក្តីណែនាំដោយឡែក។

ធនាគារជាតិនៃកម្ពុជាអាចកំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្នតឹងរ៉ឹងពាក់ព័ន្ធនឹងលក្ខខណ្ឌដើមទុនសម្រាប់ទ្រព្យសកម្មគ្រីបតូ តាមករណីចាំបាច់។

**ប្រការ ១៦.-**

ធនាគារពាណិជ្ជអាចកាន់កាប់អ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ ក្រុម១ក (មុនថ្លឹងហានិភ័យ) ជាអតិបរមា ៥% នៃដើមទុនថ្នាក់ទី១ទូទៅសរុប និងអ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ ក្រុម១ខ (មុនថ្លឹងហានិភ័យ) ជាអតិបរមា ៣% នៃដើមទុនថ្នាក់ទី១ទូទៅសរុប។

**ប្រការ ១៧.-**

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យធនាគារពាណិជ្ជរក្សាដើមទុនបន្ថែមសម្រាប់ហានិភ័យផ្សេងទៀត ដូចជា ហានិភ័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា (Infrastructure risk) ក្រៅពីហានិភ័យប្រតិបត្តិការ ហានិភ័យឥណទាន ឬហានិភ័យទីផ្សារដែលបានកំណត់នៅក្នុងក្របខ័ណ្ឌដើមទុនបទប្បញ្ញត្តិអប្បបរមា។

**ប្រការ ១៨.-**

ធនាគារពាណិជ្ជត្រូវរាយការណ៍អ៊ិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ ស្របតាមកាតព្វកិច្ចរាយការណ៍នៃបទប្បញ្ញត្តិពាក់ព័ន្ធ។ បន្ថែមពីនេះ ធនាគារពាណិជ្ជត្រូវរាយការណ៍ជាប្រចាំត្រីមាសអំពីលក្ខណៈ និងតម្លៃទ្រព្យសកម្មគ្រីបតូ តាមទម្រង់របាយការណ៍ដូចមានភ្ជាប់ក្នុងបរិសិដ្ឋ។

## ជំពូកទី ៤
## សេវាទ្រព្យសកម្មគ្រីបតូ

**ប្រការ ១៩.-**

ធនាគារពាណិជ្ជ ឬគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលមានបំណងផ្តល់សេវាទ្រព្យសកម្មគ្រីបតូមួយ ឬច្រើនដូចមានកំណត់ក្នុងប្រការ ២០ នៃប្រកាសនេះត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌសម្រាប់ការស្នើសុំការអនុញ្ញាតនឹងត្រូវកំណត់ដោយប្រកាសដោយឡែក។

នីតិបុគ្គលទាំងឡាយណាដែលមានបំណងផ្តល់សេវាទ្រព្យសកម្មគ្រីបតូណាមួយ ឬច្រើនក្នុងនាមជាគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ ដូចមានកំណត់ក្នុងប្រការ ២០ នៃប្រកាសនេះ ត្រូវស្នើសុំអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណនឹងត្រូវកំណត់ដោយប្រកាសដោយឡែក។

**ប្រការ ២០.-**

គ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ អាចផ្តល់សេវាមួយ ឬច្រើន ដូចខាងក្រោម៖

១. ការប្តូរទ្រព្យសកម្មគ្រីបតូ៖ ជាការប្តូរទ្រព្យសកម្មគ្រីបតូទៅជារូបិយវត្ថុ/រូបិយប័ណ្ណ (off-ramp) ឬពីរូបិយវត្ថុ/រូបិយប័ណ្ណទៅជាទ្រព្យសកម្មគ្រីបតូ (on-ramp) ឬការប្តូរទ្រព្យសកម្មគ្រីបតូមួយទៅជាទ្រព្យសកម្មគ្រីបតូមួយផ្សេងទៀត។

២. ការផ្ទេរទ្រព្យសកម្មគ្រីបតូ៖ ជាប្រតិបត្តិការផ្ទេរទ្រព្យសកម្មគ្រីបតូពីអាសយដ្ឋាន ឬគណនីគ្រីបតូមួយទៅអាសយដ្ឋាន ឬគណនីគ្រីបតូមួយផ្សេងទៀត (Cryptoasset address or account)។

៣. ការរក្សាទុក ឬគ្រប់គ្រងទ្រព្យសកម្មគ្រីបតូ ឬឧបករណ៍ផ្សេងៗពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ៖ ជាសេវាក្នុងការ (១) ការពារកាបូបទ្រព្យសកម្មគ្រីបតូរបស់អតិថិជន និង/ឬ (២) គ្រប់គ្រងកាបូបទ្រព្យសកម្មគ្រីបតូរបស់អតិថិជន។ គ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ អាចធ្វើប្រតិបត្តិការ ឬផ្ទេរទ្រព្យសកម្មគ្រីបតូពីផ្ទាល់របស់ខ្លួនជំនួសឱ្យអតិថិជន។ គ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ អាចគ្រប់គ្រង "ផ្តាច់មុខ" នៃលេខសម្ងាត់ (Private key) ដែលភ្ជាប់ជាមួយទ្រព្យសកម្មគ្រីបតូរបស់អតិថិជន ឬគ្រប់គ្រងផ្តាច់មុខលើកិច្ចសន្យាឆ្លាត (Smart contracts) នៃទ្រព្យសកម្មគ្រីបតូរបស់អតិថិជន។

**ប្រការ ២១.-**

គ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ មិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចខាងក្រោម៖

១. ប្រើប្រាស់ទ្រព្យសកម្មគ្រីបតូរបស់អតិថិជនសម្រាប់គោលបំណងអាជីវកម្មផ្ទាល់ខ្លួន ផ្តល់មធ្យោបាយផ្តល់កម្ចី និងឱ្យខ្ចី (Staking) ទ្រព្យសកម្មគ្រីបតូរបស់អតិថិជន

២. ធ្វើសកម្មភាព ឬផ្តល់សេវាណាមួយដែលផ្សព្វផ្សាយ ឬផ្តល់មធ្យោបាយសម្រាប់ប្រើប្រាស់ទ្រព្យសកម្មគ្រីបតូ ក្នុងការទូទាត់ទំនិញ និងសេវាកម្ម និង

៣. ផ្សាយពាណិជ្ជកម្មទ្រព្យសកម្មគ្រីបតូជាក់លាក់ណាមួយ (ប៉ុន្តែអាចផ្សាយពាណិជ្ជកម្មសេវាកម្មរបស់ខ្លួន)។

## ជំពូកទី ៥
## ទណ្ឌកម្មនិងពិន័យ

**ប្រការ ២២.-**

ធនាគារពាណិជ្ជ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២៣.-**

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជាអាចដាក់ពិន័យ ដូចខាងក្រោម៖

១. ធនាគារពាណិជ្ជដែលមិនគោរពតាមបញ្ញត្តិដូចមានកំណត់ក្នុងប្រការ ១២ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាប្រាក់ចំនួន ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ក្នុង ១ (មួយ) ប្រតិបត្តិការ

២. ធនាគារពាណិជ្ជដែលមិនគោរពកម្រិតកំណត់ដូចមានកំណត់ក្នុងប្រការ ១៦ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាប្រាក់ចំនួនចាប់ពី ២០.០០០.០០០ (ម្ភៃលាន) រៀលរហូតដល់ចំនួន ៥០០.០០០.០០០ (ប្រាំរយលាន) រៀល

៣. ធនាគារពាណិជ្ជដែលមិនគោរពកាតព្វកិច្ចរាយការណ៍ ដូចមានកំណត់ក្នុងប្រការ ១៨ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ និង

៤. ធនាគារពាណិជ្ជ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ ដែលល្មើសនឹងបញ្ញត្តិផ្សេងៗទៀតក្រៅពីចំណុច (១) (២) និង (៣) នៃប្រការនេះ នឹងត្រូវទទួលរងពិន័យជាប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យកែតម្រូវផុតកំណត់។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៥.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គនាយកប្រតិបត្តិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់ធនាគារពាណិជ្ជ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២៤

**ទេសាភិបាល**

ជា សិរី

**កន្លែងទទួល៖**
- ដូចប្រការ ២៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# បរិសិដ្ឋ

## របាយការណ៍ប្រចាំត្រីមាស ស្តីពី អិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ

## Quarterly Report on Cryptoasset Exposures

លេខសម្គាល់របាយការណ៍

Report ID

ជំនាន់របាយការណ៍

Report Version

កាលបរិច្ឆេទ

As at

ឈ្មោះគ្រឹះស្ថាន

Institution's Name

អត្រាប្តូរប្រាក់ក្នុង ១ ដុល្លារអាមេរិក = X រៀល

Exchange Rate 1 USD = X Riel

ឯកតាគិតជាលានរៀល

In million Riels

| ប្រភេទអិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូ<br>Nature of cryptoasset exposures | អិចស្ប៉ូស៊ើទ្រព្យសកម្មគ្រីបតូមុនថ្លឹងហានិភ័យ<br>Exposure value before risk-weighted | | សរុប<br>Total<br>(c)=(a)+(b) |
|---|---|---|---|
| | កិច្ចបញ្ជិកាធនាគារ<br>Banking book (a) | កិច្ចបញ្ជិកាទីផ្សារ<br>Trading book (b) | |
| ទ្រព្យសកម្មគ្រីបតូ ក្រុម១ក<br>Cryptoasset Group 1a | | | |
| eg. X Bonds | | | |
| | | | |
| | | | |
| | | | |
| សរុបទ្រព្យសកម្មគ្រីបតូ ក្រុម១ក<br>Total Exposure of Cryptoasset Group 1a | | | |
| ទ្រព្យសកម្មគ្រីបតូ ក្រុម១ខ<br>Cryptoasset Group 1b | | | |
| eg. Stablecoin A | | | |
| | | | |
| | | | |
| | | | |
| សរុបទ្រព្យសកម្មគ្រីបតូ ក្រុម១ខ<br>Total Exposure of Cryptoasset Group 1b | | | |
| ដើមទុនថ្នាក់ទី១ទូទៅសរុប (ដកស្រង់ចេញពីរបាយការណ៍ប្រចាំខែស្តីពីដើមទុនបទប្បញ្ញត្តិ)<br>Total CET1 (From Monthly Report on Regulatory Capital) | | | |
| សរុបទ្រព្យសកម្មគ្រីបតូ ក្រុម១ក ធៀបនឹងដើមទុនថ្នាក់ទី១ទូទៅសរុប<br>Total Exposure of Cryptoasset Group 1a to Total CET1 | | | |
| សរុបទ្រព្យសកម្មគ្រីបតូ ក្រុម១ខ ធៀបនឹងដើមទុនថ្នាក់ទី១ទូទៅសរុប<br>Total Exposure of Cryptoasset Group 1b to Total CET1 | | | |